❶

# គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ



ស្រះចាស់

១.ការរៀបចំស្រះមុនដាក់ត្រីចិញ្ចឹម

- សម្ភារៈមាន ម៉ាស៊ីនបូមទឹកមួយកំប្លេរ កំបោរ ជីគីមី ជីលាមកគោ កំលាំងពលកម្ម

  ក ស្រះចាស់:

- បូមពង្រីងចាប់ពពួកត្រីកាច ស្តារភក់ឲ្យនៅត្រឹម ១-២តឹក សំអាតស្មៅ លុបរន្ធក្តាម កង្កែប ពស់នៅតាមជើងទេរ រៀបចំជួសជុលជើងទេរ និង ភ្លឺស្រះ ពី ១-២ម អាស្រ័យលើប្រភេទដី
- កំបោរស បរិមាណ ១០គក្រ/១០០ម² បាចពាសពេញផ្ទៃស្រះ រួចហាល ៣ថ្ងៃ
- ជីលាមកគោ ៥០គក្រ/១០០ម²
- ជីគីមី (អ៊ុយរ៉េ ០.៧គក្រ និង ដេអាប៉េ ០.៣គក្រ)/១០០ម²



ល្បាយជី អ៊ុយរ៉េ និង ដេអាប៉េ



សកម្មភាពស្តារភក់បាតស្រះ





សកម្មភាពលាយកំបោរសំលាប់ត្រីកាច និងពពួកសត្វចង្រៃក្នុងស្រះ





សកម្មភាពបាចជីលាមកគោទ្រាប់បាតស្រះដើម្បីបង្កើតចំណីធម្មជាតិ

# គម្រោងបណ្ដាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប




**<u>ខ ស្រះថ្មី</u>** របៀបជីកស្រះគឺត្រូវ

- ✓ កំណត់ទំហំស្រះ ១០០-៥០០ម$^{២}$
- ✓ លក្ខណៈភ្លឺស្រះ ៦០សម
- ✓ កំណត់ទំហំខ្នងភ្លឺ
- ✓ ជើងទេរភ្លឺស្រះ
- ✓ ជើងទេរស្រះ ពី ២.៥០-៣ម
- ✓ កំពស់ខ្នងភ្លឺស្រះ។

**២ ការដាក់កូនត្រីចិញ្ចឹម**

**ក ប្រភេទត្រីដាក់ចិញ្ចឹម**

- ប្រភេទត្រីងាយស្រួលចិញ្ចឹម ងាយរកពូជមកចិញ្ចឹម ធន់នឹងជំងឺ ស៊ីចំណីធម្មជាតិ និងចំណីបន្ថែមដែលអាចរកបាន មានតម្លៃក្នុងទីផ្សារ ប្រជាជននិយមបរិភោគ
- ឆ្ពិន ទីឡាព្យា កាបមញ្ញ កាមឥណ្ឌា កាបស កន្ធរ

**ខ ការពិនិត្យគុណភាពកូនត្រីពូជ**

- លក្ខណៈកូនត្រីពូជល្អ ៖ សកម្មភាពហែលរហ័សរហួន
- ពេលឃើញមនុស្ស ឬ សត្រូវ កូនត្រីមានសកម្មភាពហែលគេចខ្លួនយ៉ាងលឿនចុះទៅបាតស្រះ
- ករណីហែលផ្ដុំក្បាលគ្នានៅត្រង់ចំណុចកណ្ដាលស្រះមុនពេលថ្ងៃរះ និង ក្រោយថ្ងៃរះហែលចុះទៅស្រទាប់ទឹកបាតស្រះ ។



ត្រីទីឡាព្យាក្រហម



ត្រីកាបសាមញ្ញ



ត្រីទីឡាព្យា



ត្រីទីឆ្ពិន



ត្រីកាបឥណ្ឌា



ពូជត្រីទីឡាព្យាក្រហមល្អ

# គម្រោងបញ្ជ្រាបបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប









កូនត្រីពូជអូសចេញពីស្រះផ្សាំ   ការផ្សាំកូនត្រីពេលដឹកជញ្ជូន   ការវិចខ្ចប់កូនត្រីពូជ









សកម្មភាពដឹកជញ្ជូនកូនត្រីពូជ   សកម្មភាពប្រគល់កូនត្រីពូជជូនកសិករ   សកម្មភាពលែងកូនត្រីចូលក្នុងស្រះ







### ៣.៤ ដង់ស៊ីតេត្រីដាក់ចិញ្ចឹម

- ដង់ស៊ីតេ(៣ក្បាល/ម២ ) និងមានទំហំសមស្រប
- (៥-១០សម) ចិញ្ចឹមពាក់កណ្តាលប្រពលវប្បកម្ម ។
- ដង់ស៊ីតេចិញ្ចឹមសមស្របច្រើនបំផុត(៥ក្បាល/ម២ )

### ៣.៥ ចំនួនកូនត្រីដាក់ចិញ្ចឹម

- ករណីត្រីឆ្ពិនជាប្រភេទសំខាន់ ៖
  - ឆ្ពិន=៥០% ទីឡាព្យា=៤០% និង
  - កាបសាមញ្ញ /កាបឥណ្ឌា=១០%
- ករណីត្រីឆ្ពិនជាប្រភេទសំខាន់ ៖
  - ទីឡាព្យា=៥០% ឆ្ពិន=៤០% និង
  - កាបសាមញ្ញ /កាបឥណ្ឌា=១០%

# គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប










### ៣.៦ ទំហំកូនត្រីសមស្រប

- ទីឡាព្យា ៖ ៥សម-៨សម
- កាបតណ្ណា ៖ ៨សម-១០សម
- ឆ្ពិន ៖ ៥សម-៨សម
- កាបសាមញ្ញ ៖ ៥សម-៨សម







រូបភាពផ្សេងៗ នៃរណ្តៅជី







រូបភាពផ្សេងៗនៃការរៀបចំរណ្តៅជីកំប៉ុស្តិ៍

### ៣.៧ ការដាក់ជីក្រោយដាក់ចិញ្ចឹម

ក្រោយពីដាក់កូនត្រីចិញ្ចឹមរយៈពេលពី ១០-១៥ថ្ងៃ ត្រូវពិនិត្យមើលទឹកស្រះ បើពិនិត្យឃើញទឹកស្រះព័ណបៃតងចាស់ មានន័យថាស្រះមានចំណីធម្មជាតិប្លង់តុង តែបើឃើញទឹកស្រះលែងមានព័ណបៃតង នោះយើងត្រូវបន្ថែមជីដែលបានរៀបចំក្នុងរណ្តៅស្រាប់។

#### ៣.៧.១ ជីធម្មជាតិ

លាមកគោ/ក្របី ជ្រូក មាន់/ទា ពពួករុក្ខជាតិបៃតង(ទន្ទ្រានខែត្រ ផ្ទី សង្កែកន្ទុំថេត...។ វិធីសាស្ត្រធ្វើជីកំប៉ុស្តិ៍ធម្មជាតិ មានដូចខាងក្រោមៈ

- **ការជីករណ្តៅជី** មានទំហំ=១.៥មx២មx០.៨ម អាចធ្វើទៅតាមលទ្ធភាពកសិករដូចជាៈ ជីកជារណ្តៅផ្ទាល់ដី ប្រើពាង លូ/ខ្ទាះអណ្តូងក៏បាន ។ នៅបាតរណ្តៅត្រូវធ្វើយ៉ាងណាកុំឲ្យទឹកជីជ្រាបទៅក្រោមបាន។ រណ្តៅជីត្រូវភ្ជាប់ទុយោចន្លោះប្រហែល ២ តឹកពីបាតរណ្តៅ ដោយមាន វ៉ាន ឬឆ្នុក បិទ/បើក ដើម្បីបង្ហូរទឹកជីទៅក្នុងស្រះ។
- **ការរៀបចំកំប៉ុស្តិ៍ក្នុងរណ្តៅជី**
  - បរិមាណលាមកគោ មាន់ ទា =១០០គក្រ/១០០ម² និង
  - បរិមាណរុក្ខជាតិបៃតង (ទន្ទ្រានខែត្រ ផ្ទី សង្កែ កន្ទុំថេត...) គឺ ៨០គក្រ/១០០ម² ។

# គម្រោងបណ្តាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប



សកម្មភាពថ្លឹងជីគីមី



ការថ្លឹងជីអ៊ុយរ៉េតាមទំហំស្រះ



ល្បាយជីអ៊ុយរ៉េ និងជីដេអាប៉េ

### ៣.៧.២ ជីគីមី

ជីគីមីក៏មានសារៈសំខាន់ក្នុងការបង្កើតប្លង់តុង ។
បរិមាណជីគីមីប្រើប្រាស់សំរាប់ស្រះចិញ្ចឹមត្រីគឺ:

- ជីអុយរ៉េ ០.៧ គក្រ ក្នុង១០០ម$^{២}$ និង
- ជីដេអាប៉េ ០.៣ គក្រ ក្នុង១០០ម$^{២}$

មុនពេលដាក់ជី ត្រូវលាយ អុយរ៉េ និង ដេអាប៉េ ជាមួយទឹករួចកូរឲ្យរលាយ



ទឹកស្រះព៌ណ៌បៃតងចាស់



ទឹកស្រះព៌ណ៌បៃតងខ្ចី



ទឹកស្រះល្អក់



ទឹកស្រះថ្លា

## ៤ ការគ្រប់គ្រងគុណភាពទឹក

ក្រោយពីដាក់កូនត្រីចិញ្ចឹម រយៈពេលពី១០-១៥ថ្ងៃ យើងត្រូវពិនិត្យគុណភាពទឹកស្រះឡើងវិញបើឃើញថាទឹកលែងមានពណ៌បៃតង នោះយើងត្រូវបន្ថែមជីភ្លាមដោយប្រើរណ្តៅដែលបានរៀបចំទុកជាស្រេច។

### ៤.១ ការពិនិត្យពណ៌ទឹកដោយភ្នែកទទេ

- ទឹកស្រះមានពណ៌បៃតងខ្ចី មានន័យថា កកើតចំណីធម្មជាតិគ្រប់គ្រាន់
- ទឹកស្រះមានពណ៌បៃតងចាស់ មានន័យថា កកើតចំណីធម្មជាតិច្រើនពេក ដូច្នេះត្រូវបញ្ឈប់ការដាក់ជីធម្មជាតិមួយរយៈសិនបើមិនដូច្នេះទេនឹងធ្វើឲ្យត្រីពុល ឬងាប់ ។
- ទឹកស្រះល្អក់ដោយសារដី នោះពុំមានចំណីធម្មជាតិទេ ជាហេតុធ្វើឲ្យត្រីធំធាត់យឺត
- ទឹកថ្លាមានន័យថា ខ្សត់ចំណីធម្មជាតិ ដូច្នេះត្រូវបន្ថែមជី

# គម្រោងបណ្តាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប





សកម្មភាពកសិករពិនិត្យគុណភាពទឹក និង វាស់ pH ទឹកដោយប្រើក្រដាសទួណឺសុល





សកម្មភាពកសិកររៀបចំជីកំប៉ុស្ត៍ និងបង្ហូទឹកជីចូលក្នុងស្រះចិញ្ចឹមត្រី

**ប៉េហាស និងប្រសិទ្ធិភាព ទៅលើការរស់នៅរបស់ត្រី**

| ប៉េហាស(pH) | ប្រសិទ្ធិភាព |
|---|---|
| ៤ | អាស៊ីតខ្លាំង |
| ៤-៦ | ត្រីលូតលាស់យឺត |
| ៦-៩ | ត្រីលូតលាស់ល្អប្រសើរ |
| ៩-១១ | ត្រីលូតលាស់យឺត(រយៈពេលយូរទៅនាំអោយត្រីងាប់ |
| ១១+ | អាល់កាឡាំងខ្លាំង |

## ៤.៣ ការផ្តល់ចំណី

ចំណីមានពីរប្រភេទៈ ចំណីធម្មជាតិ និងចំណីបន្ថែម។

### ៤.៣.១ ចំណីធម្មជាតិ

- មានដូចជា ប្លង់តុងសត្វ ប្លង់តុងរុក្ខជាតិនិងសត្វរស់នៅស្រទាប់បាត មានខ្យងខ្ចៅជន្លេនក្រហមជាដើម។
- ចំណីធម្មជាតិ គឺកំប៉ុស្ត៍លាមកគោ/ក្របី មាន់/ទា ជ្រូក និងពពួករុក្ខជាតិបៃតងជាដើម ឬអាចជាចំណីបន្ថែមផងដែរ។ បើកបង្ហូរទឹកជីដោយផ្ទាល់ចេញពីរណ្តៅជីឬដងបាចទៅលើផ្ទៃស្រះធ្វើដូចនេះទឹកជីមានល្បាយសព្វពេញស្រះ នៅពេលដែលមានកំដៅថ្ងៃល្អ រយៈពេល ២-៣ ថ្ងៃក្រោយមកប្លង់តុងសត្វ និង ប្លង់តុងរុក្ខជាតិបានកកើតពេញស្រះដែលជាចំណីធម្មជាតិសំរាប់ត្រី។

# គម្រោងបញ្ជ្រាបបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

## សកម្មភាពកសិករៀបចំ ចំណីបន្ថែម  សំរាប់ការចិញ្ចឹមត្រី


កាកសំណល់បន្លែបៃតង


កណ្តៀរ


ចកបាយទា


ចំណីផ្សំពី កន្ទក់ ម្សៅត្រី ត្រកួន កាកដូង


ម្សៅត្រី


កន្ទក់


កាកដូង


ត្រកួន


កាកសំណល់ត្រី

### ៤.៣.២ ចំណីបន្ថែម

- បានមកពីការផ្សំចំណីច្រើនប្រភេទដូចជាៈ កន្ទក់ ចុងអង្ករ ម្សៅត្រី ពោត សណ្តែក ឬចំណីគ្រាប់ជាដើម ។
- ចំណីដែលអាចរកបាននៅក្នុងភូមិមាន ចកបាយទា ចៃទឹក កណ្តៀរ ជន្លេន កាកសំណល់ផ្ទះបាយ កាកសំណល់បន្លែ និងកាកសំណល់ពីទីសត្តឃាដ ។ល។
- ផ្តល់ចំណីដែលផ្សំពីកន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្តែក ត្រូវចំអិនឲ្យឆ្អិន ទុកឲ្យត្រជាក់រួច ពូតជាដុំដាក់ក្នុងកញ្ច្រែងពន្លិចក្នុងទឹកជម្រៅ ០.៥ ម៉ែត្រ។
- ត្រូវកំណត់ទីតាំងផ្តល់ចំណីឱ្យបានច្បាស់លាស់
- បរិមាណចំណីផ្តល់ឲ្យត្រីស៊ីប្រែប្រួលទៅតាមទំហំត្រី គឺពី ៣ ទៅ៥% នៃទំងន់ត្រីសរុបក្នុងស្រះ
- ផ្តល់ចំណីជាទៀងទាត់បរិមាណពី ២០-២៥គក្រ/ស្រះ ទំហំពី ៣០០-៥០០ម$^{២}$ /ថ្ងៃ នៅចន្លោះម៉ោង ៩-១១ព្រឹក និងពេល

# គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប



ជញ្ជីងទំងន់ ១គក្រ



បន្ទាត់ខ្នាតជា ស.ម



តសំណាញ់ក្រឡាញឹក



ចានដែកដាក់ត្រី



ទូណឺសុលវាស់ pH



សៀវភៅកត់ត្រាទិន្នន័យ

### ៥ តាមដានការលូតលាស់ត្រី

ធ្វើរៀងរាល់១ខែម្តង ដើម្បីត្រួតពិនិត្យទៅលើប៉ារ៉ាម៉ែត្រសំខាន់ៗ ដែលទាក់ទងនឹងកត្តាធំធាត់របស់ត្រី នោះគឺ pHទឹក គុណភាពទឹក ជាដើម។ល។

សកម្មភាពនេះអាចឲ្យយើងដឹង:

- ត្រួតពិនិត្យអំពីជំងឺត្រី
- អត្រាលូតលាស់ត្រី គណនាបរិមាណចំណីបន្ថែមដែលត្រូវផ្តល់ ទៅតាមទំហំម៉ាសរបស់ត្រី
- ប៉ាន់ស្មាន/អត្រាគង់វង្សត្រីក្នុងស្រះ

### ៥.១ ត្រៀមរៀបចំសំភារៈ

- ឧបករណ៍សំរាប់ចាប់ត្រី- មានថ្នងដង សំណាញ់ អួនសំរាប់កៀរ
- ឧបករណ៍សំរាប់វាស់ ថ្លឹង- បន្ទាត់មានក្រឹត(សង់ទីម៉ែត្រ) ជញ្ជីងទំងន់ (១ ឬ ២ គីឡូក្រាម)
- សៀវភៅកត់ត្រាទិន្នន័យ
- ឧបករណ៍សំរាប់វាស់ pH ទឹក

# គម្រោងបញ្ជ្រាបបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប



ទំងន់ត្រីឆ្ពិនចិញ្ចឹម ២ខែ



ទំងន់ត្រីកាបសាមញ្ញចិញ្ចឹម ២ខែ



ទំងន់ត្រីទីឡាព្យាចិញ្ចឹម ២ខែ



ប្រវែងត្រីឆ្ពិនចិញ្ចឹម ២ខែ



ប្រវែងត្រីកាបសាមញ្ញចិញ្ចឹម ២ខែ



ប្រវែងត្រីទីឡាព្យាចិញ្ចឹម ២ខែ

## ៥.២ ការយកគំរូ និង វាស់ថ្លឹងត្រី

ចាប់ត្រីដោយប្រើឧបករណ៍សំណាញ់  នៅទីតាំងខុសៗគ្នាចំនួន៣កន្លែងនៃស្រះ ការវាស់ថ្លឹងប្រភេទត្រី ទីឡាព្យា ឆ្ពិន និងកាបសាមញ្ញ។

- រៀបចំអូនដាក់ក្នុងទឹកនៅនឹងកែងស្រះជាស្រេច គឺធ្វើលើទីតាំងផ្តល់ចំណីនោះដែលអាចយើងចាប់ត្រីពីក្នុងសំណាញ់យកមកវ៉ាស់ថ្លឹ ។
- ថ្លឹងទំងន់ និងវ៉ាស់ប្រវែងរួចកត់ត្រាចូលក្នុងសៀវភៅ។
- ការយកគំរូត្រីត្រូវ យកនៅ៣ ទីតាំងខុសៗគ្នា ដែលមួយលើកៗយកពី ១០-២០ត្រីតាមប្រភេទនីមួយៗ
- ក្នុងករណីត្រីមានរោគសញ្ញា  ឬជំងឺត្រូវយកចេញដើម្បីសាកសួរអ្នកជំនាញ

# គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

### ៦.១ ការប្រមូលផលរំលោះ

- ជាទូទៅ ការចិញ្ចឹមត្រីក្នុងស្រះចំរុះអាចប្រមូលផលបានចាប់ពីរយៈពេល ៨ខែ-១ឆ្នាំ នឹងត្រូវប្រមូលផលយកទៅលក់នៅទីផ្សារ និងប្រើប្រាស់សំរាប់ចំណីអាហារក្នុងគ្រួសារ។
- ការប្រមូលផលរំលោះ គឺគួរចាប់ផ្តើមដំណើរការ បន្ទាប់ពីចិញ្ចឹមបានរយៈពេល ពី២ ទៅ ៣ ខែ ជាបណ្តើរៗ ដោយចាប់រំលោះកូនត្រីទីឡាព្យា ចេញយកទៅផ្សាំក្នុងហាប៉ា ឬ ស្រះទុកធ្វើពូជ គឺដើម្បី ឲ្យដង់ស៊ីតេស្រះមានទំហំទូលាយ សំរាប់ប្រភេទទាំង៣ ឆ្ពិន ទីឡាព្យា និងកាសាមញ្ញ/កាបតណ្ហា លូតលាស់បានលឿន។

### ៦.២ ការប្រមូលផលសរុប

ការប្រមូលផល ចាប់ផ្តើមបន្ទាប់ពីបានចិញ្ចឹមរយៈពេល៨ ឡើងទៅ ដែលពេលនោះ ត្រីមានទំហំកាន់តែធំ ជាមធ្យមទំងន់ចាប់ពី ២៥០ក្រាម ទៅ ៣៥០ក្រាម ក្នុងមួយក្បាល អាចយកទៅលក់ក្នុងទីផ្សារបាន និងមានតម្លៃខ្ពស់។ ដើម្បីឲ្យការប្រមូលផល សរុបនេះទទួលបានផលចំណេញច្រើននោះ យើងគួរធ្វើឡើងនៅពេល៖

- ប្រមូលផលត្រីចិញ្ចឹមបានរយៈពេល ពី ៨ ខែឡើងទៅ
- ត្រីទំងន់ចាប់ពី ២៥០ក្រាម ទៅ ៣៥០ក្រាម ក្នុង១ក្បាល
- ប្រមូលផលត្រីនៅរដូវខ្សត់ត្រី ឬរដូវបិទនេសាទ
- ជាពិសេសនៅពេលដែលតម្លៃត្រីនៅទីផ្សារបានថ្លៃ
- លក់ឲ្យអ្នកហូបក្នុងតំបន់ និងខេត្ត ដើម្បីផ្សព្វផ្សាយលទ្ធផល និងពង្រីកការចិញ្ចឹមត្រី

### ៦.៣ បច្ចេកទេសប្រមូលផល

គួរតែដំណើរការនៅពេលព្រឹក លក្ខណៈបរិស្ថានស្រះល្អ និងចំពេលតម្លៃទីផ្សារបានថ្លៃ ពេលប្រមូលផលត្រីត្រូវដាក់ដោយឡែកពីគ្នាគឺត្រីធំ និងត្រីតូចដើម្បីងាយស្រួលលក់នៅតាមទីផ្សារ។

- ប្រើអួនអួសក្រឡា១-១.៥សម
- ករណីទឹកនៅជ្រៅអាចបូមទឹកចេញខ្លះដើម្បីងាយស្រួលប្រមូលផល
- ប្រើម៉ាស៊ីនបូមទឹកពង្រីង រួចចាប់ ដោយត្រៀមសំភារៈសំរាប់ទុកដាក់ប្រោះត្រី
- ប្រមូលផលហើយកសិករ គួរតែស្តារភក់បាតស្រះ និងជួសជុលស្រះឲ្យបានល្អ ទាន់ពេលដីនៅសើមសំរាប់ការដាក់ត្រីចិញ្ចឹមបន្តទៀត ។

**តារាងតាមដានទំងន់ និង តំលៃទីផ្សារត្រី**

# គម្រោងបណ្តាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

| តារាងចំណាយ | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ថ្ងៃខែឆ្នាំ | ប្រភេទមុខចំណាយ | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
| | | បូមទឹកចេញ/ចូលស្រះ | | | | |
| | | ទិញកំបោរ | | | | |
| | | ជី គីមី | | | | |
| | | កូនត្រីពូជ | | | | |
| | | ចំណី | | | | |
| តារាងចំណូល | | | | | | |
| ល.រ | ថ្ងៃខែឆ្នាំ | ប្រភេទមុខចំណូល | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
| | | លក់កូនត្រីទីឡាព្យា | | | | |
| | | ត្រូចាប់ហូប | | | | |
| | | ត្រីឲ្យគេ | | | | |
| | | លក់ត្រីសាច់ | | | | |
| | | ទុកពូជ | | | | |

**ប្រាក់ចំណេញ (ក្នុង១វដ្តនៃការចិញ្ចឹម)= ចំណូលសរុប-ចំណាយសរុប**